**THE SCHOOL DISTRICT OF PHILADELPHIA**

# GIRARD ACADEMIC MUSIC PROGRAM

**2136 RITNER STREET**

**PHILADELPHIA, PA 19145**

Ms. Jovan A. Moore, *Principal*
Bianca Gillis, *Co-Principal*

Office: 215-400-8230
Fax: 215-400-8231

ជូនចំពោះ មាតាបិតា/អាណាព្យាបាលៈ

នៅឆ្នាំ ២០១៨ ច្បាប់លេខ 158 ត្រូវបានចុះហត្ថលេខាដោយអភិបាលរដ្ឋ ដែលចែងពីតម្រូវការបញ្ចប់ការសិក្សារបស់រដ្ឋ ដែលចាប់ផ្តើមមានប្រសិទ្ធិភាពសម្រាប់សិស្សក្នុងឆ្នាំ ២០២៣ និងតទៅមុខទៀត។ ដើម្បីបញ្ចប់ការសិក្សាពីវិទ្យាល័យ សិស្សត្រូវបំពេញតាមតម្រូវការបញ្ចប់ការសិក្សាក្នុងតំបន់ទាំងអស់ ដែលទាក់ទងនឹងក្រេឌីត និងវគ្គសិក្សា រួមជាមួយនឹងម្រូវការរបស់រដ្ឋដែលមានចែងក្នុងច្បាប់លេខ 158។ នៅទីក្រុងហ្វីឡាដែលហ្វ្យា តម្រូវការទាំងនោះរួមមាន ការទទួលបានក្រេឌីតសរុបចំនួន 23.5 ក្នុងវគ្គសិក្សាដែលត្រូវតាមតម្រូវការ និងបញ្ចប់ដោយជោគជ័យនៃ សេវាសិក្សាតាមការជួយអ្នកដទៃ (Service Learning Project)។

សិស្សក៏ត្រូវតែធ្វើតាមផ្លូវមួយ ក្នុងចំណោមផ្លូវទាំងប្រាំរបស់រដ្ឋ ផិនស៊ីលវេនញ៉ា ដែលបានរៀបរាប់ខាងក្រោមនេះ ដើម្បីទទួលបានសញ្ញាប័ត្រ និងបង្ហាញពីការត្រៀមខ្លួនសម្រាប់អាជីព និង/ឬ មហាវិទ្យាល័យ។ ព័ត៌មានបន្ថែមទាក់ទងនឹងតម្រូវការបញ្ចប់ការសិក្សារបស់រដ្ឋ ផិនស៊ីលវេនញ៉ា អាចមើលក្នុងគេហទំព័រ [www.philasd.org/gradreq](http://www.philasd.org/gradreq) ។

រដ្ឋបាលសាលា អ្នកផ្តល់ឱវាទនៅសាលា និងសមាជិកផ្សេងទៀតនៃក្រុមរបស់សាលានឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយសិស្សម្នាក់ៗ ដើម្បីពិនិត្យឡើងវិញ និងជួយសិស្សក្នុងការសម្រេចចិត្ត ថាតើផ្លូវមួយណាដែលល្អបំផុតដើម្បីបំពេញតាមតម្រូវការបញ្ចប់ការសិក្សាទូទាំងរដ្ឋនេះ។

សូមកុំស្ទាក់ស្ទើរក្នុងការទូរស័ព្ទមកសាលា ហើយធ្វើការណាត់ជួបដើម្បីនិយាយជាមួយអ្នកផ្តល់ឱវាទរបស់កូនលោកអ្នក ប្រសិនបើលោកអ្នកមានសំណួរអ្វីអំពីច្បាប់លេខ 158 និង/ឬ ផ្លូវរបស់កូនលោកអ្នកទៅកាន់ការបញ្ចប់ការសិក្សា។ លិខិតដាច់ដោយឡែកមួយនឹងផ្ញើទៅមាតាបិតារបស់សិស្សឆ្នាំទីបួន សិស្សឆ្នាំទីបី និងសិស្សឆ្នាំទីពីរ បច្ចុប្បន្ន ដែលផ្តល់ដំណឹងដល់ពួកគាត់អំពីស្ថានភាពបច្ចុប្បន្នរបស់សិស្សទាក់ទងនឹងតម្រូវការបញ្ចប់ការសិក្សា និងផ្លូវដែលបានណែនាំ។

ការិយាល័យទំនាក់ទំនងជាមួយក្រុមគ្រួសារ និងរៀបចំជាស្រេចសម្រាប់ការសិក្សាក្រោយពេលរៀនចប់ពីវិទ្យាល័យ (Offices of Family Engagement and Postsecondary Readiness) របស់ក្រសួងអប់រំ នឹងរៀបចំវគ្គផ្តល់ព័ត៌មានខាងក្រោមនេះនៅសប្តាហ៍ខាងមុខ ដើម្បីជួយសិស្ស និងក្រុមគ្រួសារ ឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីតម្រូវការរបស់រដ្ឋ PA ។
គេនឹងធ្វើការចុះឈ្មោះសម្រាប់ព្រឹត្តិ ការណ៍ខាងក្រោមនេះ

- វគ្គផ្តល់ព័ត៌មានសម្រាប់គ្រួសារ - ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ម៉ោង ១២ ថ្ងៃត្រង់ ដល់ ១ រសៀល (LINK)
- វគ្គផ្តល់ព័ត៌មានសម្រាប់គ្រួសារ - ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ម៉ោង ៥:៣០ ល្ងាច ដល់ ៦:៣០ ល្ងាច (LINK)
- ម៉ោងការិយាល័យសម្រាប់គ្រួសារ - ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ម៉ោង ១០ ដល់ ១១ ព្រឹក និង ៥ ដល់ ៦ ល្ងាច (LINK)
- ម៉ោងការិយាល័យសម្រាប់គ្រួសារ - ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ម៉ោង ១០ ដល់ ១១ ព្រឹក និង ៥ ដល់ ៦ ល្ងាច (LINK)

THE SCHOOL DISTRICT OF PHILADELPHIA
GIRARD ACADEMIC MUSIC PROGRAM
2136 RITNER STREET
PHILADELPHIA, PA 19145

Ms. Jovan A. Moore, *Principal*
Bianca Gillis, *Co-Principal*

Office: 215-400-8230
Fax: 215-400-8231

- វគ្គផ្តល់ព័ត៌មានរបស់ FACT - ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ម៉ោង ១០ ដល់ ១១ ព្រឹក (LINK) ម៉ោង ៦ ដល់ ៧ ល្ងាច (LINK)

## ច្បាប់លេខ 158 - ផ្លូវបញ្ចប់ការសិក្សារបស់រដ្ឋ

សិស្សដែលបញ្ចប់ការសិក្សានៅឆ្នាំ ២០២៣ និងតទៅមុខទៀត ត្រូវតែបំពេញតាមជម្រើសផ្លូវមួយ ក្នុងចំណោមជម្រើសផ្លូវខាងក្រោមនេះ ដើម្បីបំពេញតាមតម្រូវការនៃការបញ្ចប់ការសិក្សារបស់រដ្ឋ៖

***Keystone Proficiency Pathway 1***: ពិន្ទុ ស្ទាត់ជំនាញ (proficient) ឬ កម្រិតខ្ពស់ (advanced) លើការប្រឡង Keystone ទាំងបី (ពិជគណិត ១ អក្សរសាស្ត្រ និង ជីវវិទ្យា)

***Keystone Composite Pathway 2***: ទទួលបានពិន្ទុសរុបដែលពេញចិត្ត (4452) លើការប្រឡង Keystone ពិជគណិត ១ អក្សរសាស្ត្រ និង ជីវវិទ្យា (ខណៈពេលដែលទទួលយ៉ាងហោចណាស់ពិន្ទុ ស្ទាត់ជំនាញ / កម្រិតខ្ពស់ មួយ ហើយគ្មានពិន្ទុក្រោម មូលដ្ឋាន (basic) លើការប្រឡងពីរទៀត)

***Career and Technical Education Pathway 3***: CTE Concentrators (សិស្សដែលបានបញ្ចប់ 50% ឬច្រើនជាងនេះ នៃកម្មវិធី CTE ដែលបានចុះឈ្មោះរៀន)៖ ការបញ្ចប់ដោយជោគជ័យនៃតម្រូវការផ្អែកលើពិន្ទុ ដែលបានបង្កើតឡើងក្នុងតំបន់សម្រាប់មុខវិជ្ជាសិក្សា ដែលទាក់ទងនឹងការប្រឡង Keystone នីមួយៗ (ឧ. ប្រឡងជាប់វគ្គចុងក្រោយ ដែលរួមមាន ពិជគណិត ១ ជីវវិទ្យា និង អង់គ្លេស ២) និងអ្វីមួយ ក្នុងចំណោមអ្វីៗដូចខាងក្រោមនេះ៖

- ការទទួលបានសញ្ញាប័ត្រតាមការប្រកួតប្រជែងសមត្ថភាពផ្អែកលើឧស្សាហកម្ម
- ការបង្ហាញអំពីលទ្ធភាពជោគជ័យខ្ពស់លើការវាយតម្លៃតាមការប្រកួតប្រជែងសមត្ថភាពផ្អែកលើឧស្សាហកម្ម
- ការត្រៀមខ្លួនដើម្បីបន្តនៅក្នុងកម្មវិធីសិក្សារបស់ CTE Concentrator

***Alternate Assessment Pathway 4***: ការបញ្ចប់ដោយជោគជ័យនៃតម្រូវការផ្អែកលើពិន្ទុ ដែលបានបង្កើតឡើងក្នុងតំបន់សម្រាប់មុខវិជ្ជាសិក្សា ដែលទាក់ទងនឹងការប្រឡង Keystone នីមួយៗ (ឧ. ប្រឡងជាប់វគ្គចុងក្រោយ ដែលរួមមាន ពិជគណិត ១ ជីវវិទ្យា និង អង់គ្លេស ២) និងអ្វីមួយ ក្នុងចំណោមអ្វីៗដូចខាងក្រោមនេះ៖

- ការទទួលបានពិន្ទុដែលបានបង្កើតឡើងលើការវាយតម្លៃផ្សេងទៀតដែលបានយល់ព្រម៖ SAT (1010), PSAT (970), ACT (21), ASVAB (31)
- Gold Level លើការវាយតម្លៃ ACT WorkKeys
- ការទទួលបានពិន្ទុ 3 ឬប្រសើរជាងនេះ លើការប្រឡង កម្មវិធីសិក្សាកម្រិតខ្ពស់ (Advanced Placement Program) ក្នុងមុខវិជ្ជាសិក្សាសំខាន់ៗដែលទាក់ទងនឹងការប្រឡង Keystone នីមួយៗ ដែលសិស្សមិនបានទទួលយ៉ាងហោចណាស់ពិន្ទុស្ទាត់ជំនាញ

THE SCHOOL DISTRICT OF PHILADELPHIA
**GIRARD ACADEMIC MUSIC PROGRAM**
2136 RITNER STREET
PHILADELPHIA, PA 19145

Ms. Jovan A. Moore, *Principal* Office: 215-400-8230
Bianca Gillis, *Co-Principal* Fax: 215-400-8231

- ការទទួលបានពិន្ទុ 4 ឬប្រសើរជាងនេះ លើការប្រឡងបាក់ឌុបអន្តរជាតិ (International Baccalaureate Exam) ក្នុងមុខវិជ្ជាសិក្សាសំខាន់ៗដែលទាក់ទងនឹងការប្រឡង Keystone នីមួយៗ ដែលសិស្សមិនបានទទួលយ៉ាងហោចណាស់ពិន្ទុស្ទាត់ជំនាញ
- ការបញ្ចប់ដោយជោគជ័យនៃវគ្គសិក្សាចុះឈ្មោះចូលរៀនដំណាលគ្នា (រៀននៅវិទ្យាល័យផង មហាវិទ្យាល័យផង) ក្នុងមុខវិជ្ជាសិក្សាសំខាន់ៗដែលទាក់ទងនឹងការប្រឡង Keystone នីមួយៗ ដែលសិស្សមិនបានទទួលយ៉ាងហោចណាស់ពិន្ទុស្ទាត់ជំនាញ
- ការបញ្ចប់ដោយជោគជ័យនៃកម្មវិធីមុនកម្មសិក្សា
- ការទទួលឱ្យចូលរៀននៅស្ថាប័នមិនយកកម្រៃ 4 ឆ្នាំ ដែលមានការទទួលស្គាល់នៃឧត្តមសិក្សា និងភស្តុតាងនៃសមត្ថភាពចុះឈ្មោះក្នុងវគ្គសិក្សាកម្រិតមហាវិទ្យាល័យ

***<u>Evidence Based Pathway 5</u>***: ការបញ្ចប់ដោយជោគជ័យនៃតម្រូវការផ្អែកលើពិន្ទុ ដែលបានបង្កើតឡើងក្នុងតំបន់សម្រាប់មុខវិជ្ជាសិក្សាដែលទាក់ទងនឹងការប្រឡង Keystone នីមួយៗ (ឧ. ប្រឡងជាប់វគ្គចុងក្រោយ ដែលរួមមាន ពិជគណិត ១ ជីវវិទ្យា និង អង់គ្លេស ២) និងការបង្ហាញភស្តុតាង បី (3) ដែលស្របនឹង គោលដៅ និងផែនការអាជីព របស់សិស្ស រួមទាំង៖

- អ្វីមួយ ឬលើសពីមួយ នៃអ្វីៗដូចខាងក្រោមនេះ៖
  - ការទទួលបានពិន្ទុ Silver Level លើការវាយតម្លៃ ACT WorkKeys
  - ការទទួលបានពិន្ទុ 3 ឬប្រសើរជាងនេះ លើការប្រឡងកម្មវិធីសិក្សាកម្រិតខ្ពស់ (Advanced Placement Program Exam) ណាមួយ
  - ការទទួលបានពិន្ទុ 3 ឬប្រសើរជាងនេះ លើការប្រឡងបាក់ឌុបអន្តរជាតិ (International Baccalaureate Exam) ណាមួយ
  - ការទទួលឱ្យចូលរៀននៅស្ថាប័នក្រៅពី 4 ឆ្នាំ នៃឧត្តមសិក្សា សម្រាប់វគ្គសិក្សាកម្រិតមហាវិទ្យាល័យ
  - ការទទួលបានលិខិតសម្គាល់ដែលទទួលស្គាល់ដោយឧស្សាហកម្ម
  - ការបញ្ចប់ដោយជោគជ័យនៃការចុះឈ្មោះចូលរៀនដំណាលគ្នា ឬវគ្គសិក្សាក្រោយពីវិទ្យាល័យណាមួយ
- និងភស្តុតាងបន្ថែមខាងក្រោមនេះ **មិនអាចលើសពីពីរបានទេ**៖
  - ការបញ្ចប់ដោយជោគជ័យនៃ សេវាសិក្សាតាមការជួយអ្នកដទៃ (Service Learning Project)
  - ការទទួលបានពិន្ទុស្ទាត់ជំនាញ ឬកម្រិតខ្ពស់ លើការប្រឡង Keystone ណាមួយ
  - លិខិតធានាការងារពេញម៉ោង ឬការចូលបម្រើយោធា
  - ការបញ្ចប់ដោយជោគជ័យនៃកម្មសិក្សា ឬកម្មវិធីរៀនផង ធ្វើការផង
  - ការអនុលោមតាមតម្រូវការសិក្សារបស់ NCAA’s Division II

យើងប្តេជ្ញាធានាថាមានការគាំទ្រកម្រិតខ្ពស់ចំពោះសិស្ស និងក្រុមគ្រួសារ ក្នុងការរៀបចំការបញ្ចប់ការសិក្សារបស់សិស្ស។

ដោយសេចក្តីស្មោះស្ម័គ្រ

THE SCHOOL DISTRICT OF PHILADELPHIA
GIRARD ACADEMIC MUSIC PROGRAM
2136 RITNER STREET
PHILADELPHIA, PA 19145

Ms. Jovan A. Moore, *Principal*
Bianca Gillis, *Co-Principal*

Office: 215-400-8230
Fax: 215-400-8231

Jovan A. Moore

នាយកសាលា